CDRI វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា
Cambodia Development Resource Institute

# សិក្ខាសាលាចាប់ផ្តើមគម្រោងស្តីពី ការបង្កើនការស្រាវជ្រាវ និងកិច្ចសន្ទនាគោលនយោបាយនៅប្រទេសមេគង្គ-ឡានឆាង

## សេចក្តីប្រកាសព័ត៌មាន

ក្រុងសៀមរាប ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី១៩ មិថុនា ២០១៨

វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI-វបសអ) នឹងជំណើការសិក្ខាសាលាចាប់ផ្តើមកម្មវិធីមួយស្តីពី "ការបង្កើនការស្រាវជ្រាវ និងកិច្ចសន្ទនាគោលនយោបាយនៅប្រទេសមេគង្គ-ឡានឆាង" នៅថ្ងៃទី ២១ និង ២២ ខែមិថុនា ឆ្នាំ២០១៨ នៅក្រុងសៀមរាប។

កម្មវិធីស្រាវជ្រាវរយៈពេល ២ឆ្នាំនេះ មានគោលដៅផ្តល់ភស្តុតាងជាក់ស្តែង និងជួយផ្តល់មតិផ្នែកគោលនយោបាយដល់អ្នកកសាងគោលនយោបាយនៅតាមបណ្តាប្រទេសក្នុងតំបន់មេគង្គ-ឡានឆាង។ កម្មវិធីនេះទទួលបានថវិកាពី មូលនិធិពិសេសនៃសហប្រតិបត្តិការមេគង្គ-ឡានឆាង តាមរយៈ ស្ថានទូតសាធារណរដ្ឋប្រជាមានិតចិន នៅព្រះរាជាណាចក្រកម្ពុជា និងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជា។

កម្មវិធីនេះរួមមាន គម្រោងស្រាវជ្រាវចំនួនពីរ ស្តីពី ១) ពាណិជ្ជកម្មផលិតផលកសិកម្មរវាងប្រទេសចិន និងបណ្តាប្រទេសក្នុងមហាអនុតំបន់មេគង្គ៖ ការវិភាគខ្សែសង្វាក់តម្លៃ) និង ២) ផលិតកម្មកសិកម្មតាមកិច្ចសន្យានៅក្នុងបណ្តាប្រទេសទន្លេមេគង្គ-ឡានឆាង៖ ស្វែងយល់ពីបទពិសោធន៍ និងការអនុវត្តល្អទៅលើផលិតកម្មកសិកម្មតាមបែបកិច្ចសន្យា។ គម្រោងទាំងពីរនេះ នឹងត្រូវអនុវត្តរួមគ្នាដោយស្ថាប័នស្រាវជ្រាវ និងសាកលវិទ្យាល័យនានា មកពី ៦ប្រទេស ។

សិក្ខាសាលានេះ គ្រោងមានអ្នកចូលរួមប្រមាណ ៥០នាក់ មកពីប្រទេសទាំង៦។ ឯកឧត្តម ថៃ ជុន អគ្គនាយកនៃអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនៃ ក្រសួងការបរទេសកម្ពុជា នឹងចូលរួមជាអធិបតី និងថ្លែងសុន្ទរកថាបើកសិក្ខាសាលា។

គណៈកម្មការរៀបចំសូមស្វាគមន៍ អ្នកតំណាងប្រព័ន្ធផ្សព្វផ្សាយមកចូលរួមយកព័ត៌មានអំពីសិក្ខាសាលានេះ។ សម្រាប់ព័ត៌មានបន្ថែម សូមពិនិត្យមើលក្នុងកម្មវិធីជូនភ្ជាប់។

សម្រាប់សំណួរផ្សេងៗលើការរៀបចំសិក្ខាសាលានេះ សូមទាក់ទងលោក អ៊ុំ ចាន់ថា តាម ទូរស័ព្ទលេខ (៨៥៥) ៦៦ ៥០០ ៣៣៦ ឬ តាមអ៊ីម៉ែល chantha@cdri.org.kh។

វិទ្យាស្ថាន CDRI, 56 ផ្លូវលេខ 315, ខណ្ឌទួលគោក,
ប្រអប់សំបុត្រលេខ 622 ភ្នំពេញ កម្ពុជា
ទូរស័ព្ទ: +85523881384/881701/883603/881916 ទូរសារ: +85523880734
អ៊ីមែល: cdri@cdri.org.kh គេហទំព័រ: www.cdri.org.kh